

## ការអង្កេតរបស់ធនាគារពិភពលោកជាមួយអ្នកទិញផលិតផលកម្ពុជា

នៅឆ្នាំ ២០០៤ ធនាគារពិភពលោកបានរកឃើញថា ការធានាអោយមានល័ក្ខខ័ណ្ឌការងារល្អប្រសើរនៅតាមរោងចក្រនៅកម្ពុជា គឺជាកត្តាចំបងបំផុតរបស់អ្នកទិញក្នុងការទិញផលិតផលចេញពីកម្ពុជា។ ការសិក្សារបស់ធនាគារពិភពលោកគឺមានលក្ខណៈឯករាជ្យ និងមានភាពហ្មត់ចត់ក្នុងការវាយតំលៃរបស់ខ្លួន។ តាមពិតអ្នកទិញចំបង៧នូវផលិតផលពីកម្ពុជា អោយតំលៃលើស្តង់ដារការងារជាអាទិភាពខ្ពស់បំផុត ក្នុងការសំរេចចិត្តរបស់គេ លើការទិញផលិតផលពីប្រទេសណាមួយ ហើយបានចាត់ទុកថាកម្ពុជាមានគុណសម្បត្តិប្រសើរជាងប្រទេស បង់ក្លាដេស ប្រទេសថៃ វៀតណាម និងចិន។ ការអង្កេតនោះក៏បានរកឃើញផងដែរថា អ្នកទិញប្រមាណជិត ៨០% បានចាត់ទុកថាការត្រួតពិនិត្យមើលទៅលើបទដ្ឋានការងារ ជាកត្តាសំខាន់ណាស់បន្ទាប់ពីបញ្ចប់ប្រព័ន្ធកូតា ហើយបានផ្តល់នូវការកោតសរសើរចំពោះសកម្មភាពឃ្លាំមើលរបស់អង្គការពលកម្មអន្តរជាតិ។ អ្នកទិញក៏បាននិយាយផងដែរថា បទដ្ឋានការងារដែលមានលក្ខណៈកាន់តែប្រសើរ គឺមានឥទ្ធិពលជាវិជ្ជមានលើអត្រាគ្រោះថ្នាក់ ផលិតភាពនៅកន្លែងធ្វើការ គុណភាពផលិតផល ការផ្លាស់ប្តូរការងារ និងអវត្តមានរបស់កម្មករនិយោជិត ។




*ប្រភព:* *Cambodia: Corporate Social Responsibility & the Apparel Sector Buyer Survey Results, Foreign Investment Advisory Service (World Bank Group), Washington, December 2004*

## មូលនិធិ

ការចំណាយសំរាប់សកម្មភាពឃ្លាំមើលនេះគឺមានលក្ខណៈសមរម្យពោលគឺតិចជាង ៣ ដុល្លាអាមេរិក សំរាប់កម្មករម្នាក់ក្នុងមួយឆ្នាំ ឬស្មើនឹង ២.៨០០ ដុល្លាអាមេរិក សំរាប់រោងចក្រនីមួយៗ។ រោងចក្រដែលចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនឹងបង់វិភាគទានបន្ថែមទៀតទៅលើការចំណាយ ។



សំរាប់ពេលបច្ចុប្បន្ននេះ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានទទួលមូលនិធិពីក្រសួងការងាររបស់សហរដ្ឋអាមេរិក (USDOL) ភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) រាជរដ្ឋាភិបាលកម្ពុជា និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានទទួលការណែនាំពីគណៈកម្មការត្រីភាគីមួយដែលរួមមានសមាសភាពមកពីក្រសួងរបស់រដ្ឋាភិបាល GMAC និងសហព័ន្ធសហជីពកម្ពុជា។ អ្នកទិញអន្តរជាតិ គឺជាកត្តាចំបងណាស់ ចំពោះការងាររបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ហើយមានការតាំងចិត្តយ៉ាងមុតមាំក្នុងការពិគ្រោះយោបល់ និងកសាងទំនាក់ទំនងជាមួយអ្នកទិញទាំងអស់ដែលមានការចាប់អារម្មណ៍។



## និរន្តរភាព

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានបំណងអោយមាននិរន្តរភាពក្នុងរយៈពេលវែង។ បុគ្គលិករបស់គំរោងភាគច្រើនជាជនជាតិខ្មែរស្រាប់ ហើយការងារមួយចំនួនរបស់គំរោងក៏ពាក់ព័ន្ធនឹងការកសាងសមត្ថភាពដែរ។ ផែនការមូនិធិបច្ចុប្បន្ន គឺចង់អោយគំរោងនេះអាចទ្រទ្រង់ខ្លួនដោយខ្លួនឯងផ្ទាល់ ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៩ ។ ដើម្បីបំពេញបំណងនេះ តំរូវអោយមានការតាំងចិត្តពីដៃគូសង្គម (រដ្ឋាភិបាល និយោជក និងសហជីព) ក៏ដូចជា អ្នកទិញ និងអ្នកប្រើប្រាស់ ដើម្បីធានាអោយកម្ពុជាអាចដំណើរការតទៅទៀតដោយចាប់ផ្តើមពីជោគជ័យរបស់ខ្លួន ។

### ចំពោះពត៌មានបន្ថែម សូមទាក់ទង


*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*
ផ្ទះលេខ ៩ ផ្លូវ ៣២២
សង្កាត់ បឹងកេងកង ១
ភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ: ៨៥៥-២៣ ២១២ ៨៤៧ បន្ត ១០៦
ទូរសារ: ៨៥៥-២៣ ២១២ ៩០៣
អ៊ីម៉ែល: betterfactories@ilo.org


# ‘‘‘ រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា












អង្គការ
ពលកម្ម
អន្តរជាតិ

# រោងចក្រកាន់តែប្រសើរនៅកម្ពុជា

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាកម្មវិធីពិសេសមួយរបស់អង្គការពលកម្មអន្តរជាតិ។ កម្មវិធីនេះផ្តល់ប្រយោជន៍ដល់កម្មករនិយោជិត និយោជក និងអង្គភាពរបស់គេផង។ កម្មវិធីនេះក៏ផ្តល់ផលប្រយោជន៍ផងដែរ ដល់អ្នកប្រើប្រាស់ផលិតផលនៅតាមបណ្តាប្រទេសលោកខាងលិច ព្រមទាំងជួយកាត់បន្ថយភាពក្រីក្ររបស់ ប្រទេសក្រីក្រមួយក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោក ។



កម្មវិធីនេះផ្តល់នូវគុណប្រយោជន៍បែបនេះតាមរយៈការតាមឃ្លាំមើល និង ការរាយការណ៍អំពីល័ក្ខខ័ណ្ឌការងារ នៅតាមរោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ដោយអនុលោមទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ តាមរយៈការជួយរោងចក្រសហគ្រាសក្នុងការលើកកំពស់ផលិតភាព និងតាមរយៈការធ្វើការជាមួយរដ្ឋាភិបាល និង អ្នកទិញអន្តរជាតិ ដើម្បីធានាអោយមានវដ្តនៃការរីកចំរើនប្រកបដោយភាពហ្មត់ចត់ និងតម្លាភាព ។

កម្មវិធីនេះកើតចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយរវាងសហរដ្ឋអាមេរិក និងកម្ពុជា។ ក្រោមកិច្ចព្រមព្រៀងនេះ សហរដ្ឋអាមេរិកបានសន្យាអោយកម្ពុជានាំចូលនូវផលិតផលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ជាការប្តូរនឹងការសុំអោយមានល័ក្ខខ័ណ្ឌការងារល្អប្រសើរក្នុងវិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា។ គំរោងកម្មវិធីរបស់អង្គការពលកម្មអន្តរជាតិត្រូវបានបង្កើតឡើងនៅ ឆ្នាំ២០០១ ដើម្បីជួយអោយវិស័យនេះសំរេច និងរក្សាអោយបាននូវការរីកចំរើនបែបនេះ ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កាលពីមុនមានឈ្មោះថា គំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេររបស់អង្គការពលកម្មអន្តរជាតិ។ ឈ្មោះថ្មីនេះឆ្លុះបញ្ចាំងនូវគោលបំណងបច្ចុប្បន្ន របស់គំរោងអង្គការពលកម្មអន្តរជាតិបានប្រសើរជាងមុន ។

## អំពីឧស្សាហកម្មកាត់ដេរសំលៀកបំពាក់

ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជាមានការរីកដុះដាលយ៉ាងឆាប់រហ័សនូវគ្រប់បទដ្ឋាន។ ឧស្សាហកម្មនេះបានចាប់ផ្តើមឡើងស្ទើរតែពីបាតដៃទទេនៅឆ្នាំ១៩៩៤។ តែទោះជាយ៉ាងណាក្តី វិស័យកាត់ដេរសំលៀកបំពាក់បច្ចុប្បន្ន បាននាំមកនូវប្រាក់ចំណូលប្រមាណ ៨០% នៃប្រាក់ចំណូលពីការនាំចេញរបស់កម្ពុជា។ នេះជាឧស្សាហកម្មធំបំផុតរបស់កម្ពុជា ហើយនៅឆ្នាំ ២០០៤ ឧស្សាហកម្មនេះបាននាំមកនូវប្រាក់ចំណូលប្រមាណ ១,៩ កោដិដុល្លា អាមេរិក។ គ្មានប្រទេសផ្សេងណារកប្រាក់ចំណូលពីការនាំចេញនៃឧស្សាហកម្មនេះមានបរិមាណច្រើនដូចកម្ពុជាឡើយ ។

មានកម្មករនិយោជិតជាង ២៧០.០០០ នាក់ធ្វើការនៅឧស្សាហកម្មនេះ ។ ភាគច្រើននៃកម្មករនិយោជិតទាំងនេះ ជាស្ត្រីវ័យក្មេងៗមកពីតំបន់ជនបទ។ ក្រៅពីឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នេះ ពុំសូវមានការងារសំរាប់កម្មករនិយោជិតទាំងនេះទេ ហេតុដូច្នេះហើយការងារនៅតាមរោងចក្រសហគ្រាសគឺមានតំលៃជាពិសេសសំរាប់ពួកគេ។ ការងារនៅឧស្សាហកម្មនេះ អាចនាំអោយស្ត្រីជាច្រើនរកចំណូលសំរាប់ខ្លួនគេផង និងអាចផ្ញើប្រាក់ខ្លះទៅអោយគ្រួសាររបស់គេផងសំរាប់លើកស្ទួយជីវភាពរស់នៅរបស់គ្រួសារ និងរកឱកាសផ្សេងៗទៀតរបស់គេ ។

រោងចក្រកាត់ដេរសំលៀកបំពាក់ស្ទើរតែទាំងអស់នៅកម្ពុជាគឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុនបរទេស។ ម្ចាស់រោងចក្រភាគច្រើនមកពី ហុងកុង តៃវ៉ាន់ ឬចិនប្រជាមានិត។ ក្រុមហ៊ុនរបស់សហរដ្ឋអាមេរិកទិញផលិតផលសំលៀកបំពាក់របស់កម្ពុជាប្រមាណពីរភាគបីនៃផលិតផលសរុប ហើយភាគច្រើននៃផលិតផលដែលនៅសល់ពីនោះ គឺត្រូវបានទិញដោយក្រុមហ៊ុនអឺរ៉ុប ។

# ដំណើរការផ្ទាល់របស់គំរោង

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* អនុវត្តនូវកម្មវិធីចុះត្រួតពិនិត្យតាមរោងចក្រកាត់ដេរ ដោយមិនប្រកាសអោយដឹងមុន ដើម្បីទៅពិនិត្យមើលល័ក្ខខ័ណ្ឌការងារនៅទីនោះ។ បញ្ជីត្រួតពិនិត្យរបស់អ្នកចុះឃ្លាំមើលដែលត្រូវបានរៀបចំឡើងដោយផ្អែកតាមច្បាប់ស្តីពីការងាររបស់កម្ពុជា និងបទដ្ឋាននានារបស់អង្គការពលកម្មអន្តរជាតិនោះមានរហូតដល់ជាង៥០០ចំណុចឯណោះ។ ដើម្បីធានាអោយមានភាពត្រឹមត្រូវ កម្មករនិយោជិត និងអ្នកគ្រប់គ្រង រោងចក្រ ត្រូវបានសំភាសន៍ដាច់ដោយឡែកពីគ្នា និងដោយរក្សាការសំងាត់។ ជាទូទៅការសំភាសន៍ជាមួយកម្មករនិយោជិតត្រូវបានរៀបចំឡើងនៅក្រៅឆ្ងាយពីរោងចក្រ។ អ្នកឃ្លាំមើលល័ក្ខខ័ណ្ឌការងារនោះក៏ពិភាក្សាផងដែរ ជាមួយប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពប្រចាំរោងចក្រនោះ ។

អ្នកគ្រប់គ្រងរោងចក្រត្រូវបានផ្ញើជូននូវរបាយការណ៍ជាលាយល័ក្ខណ៍អក្សរ អំពីលទ្ធផលនៃទស្សនៈកិច្ចនោះ ដែលក្នុងនោះមានភ្ជាប់នូវសំណូមពរសំរាប់កែលំអ។ សំណូមពរមានលក្ខណៈជាក់លាក់ផ្តោតចំបញ្ហានានា ដូចជាពលកម្មកុមារ សេរីភាពនៃការចូលជាសហជីព កិច្ចសន្យាការងាររបស់កម្មករ និយោជិត ប្រាក់ឈ្នួល ម៉ោងធ្វើការ សំភារៈបរិក្ខារនៅកន្លែងធ្វើការ ការគ្រប់គ្រងសំលេងនិងសុវត្ថិភាពម៉ាស៊ីន។

បន្ទាប់ពីបានចំណាយពេលខ្លះសំរាប់ពិភាក្សា និងធ្វើសកម្មភាពតាមដាន អ្នកឃ្លាំមើលនោះចុះទស្សនៈកិច្ចទៅកាន់រោងចក្រនោះម្តងទៀត ដើម្បីពិនិត្យការរីកចំរើន។ របកគំហើញដែលទទួលបានពីការចុះឃ្លាំមើលនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈរបាយការណ៍។ ឈ្មោះរបស់ក្រុមហ៊ុនត្រូវបានលើកឡើង ហើយការរីកចំរើនក្នុងការអនុវត្តន៏របស់គេត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍បន្ទាប់ពីការចុះត្រួតពិនិត្យតាមដានលើកទីពីរ ។



# ការកែលំអជាបន្តបន្ទាប់

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កំពុងបង្កើតឡើងនូវសេវានានាសំរាប់ជួយដល់ឧស្សាហកម្មនេះ ក្នុងការកែលំអ ល័ក្ខខ័ណ្ឌការងារ ដែលក្នុងពេលជាមួយគ្នានោះអាចនាំមកនូវការលើកកំពស់គុណភាព និងផលិតភាព។ ធនធាន និង ឱកាសបណ្តុះបណ្តាលជាច្រើន កំពុងត្រូវបានផ្តល់ជូនជាបន្តបន្ទាប់ដល់ឧស្សាហកម្មនេះ។ ជំរើសទាំងនោះរួមមានចាប់ពីការផ្តល់ជូននូវផ្ទាំងក្រដាសដែលចែងពីគំរូនៃការអនុវត្តន៏ល្អ រហូតដល់កម្មវិធីបណ្តុះបណ្តាលតាមម៉ូឌុលដែលមានរយៈពេល ១២ខែ។ ចាប់ពីឆ្នាំ ២០០៥ នេះទៅ ដោយមានមូលនិធិពីភ្នាក់ងារអភិវឌ្ឍន៏បារាំង (AFD) *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នឹងរៀបចំអោយមានវែបសាយថ្មីមួយ និងបង្កើតឡើងនូវធនធានសំភារៈថ្មីៗ ព្រមទាំងផ្តល់ជូននូវឱកាសបណ្តុះបណ្តាលជាច្រើនថែមទៀត ។



កិច្ចសហការនៅកន្លែងធ្វើការ រវាងថ្នាក់គ្រប់គ្រងរោងចក្រសហគ្រាស និងសហជីពគឺជាបេះដូងនៃកម្មវិធីបណ្តុះបណ្តាលរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*។ ការបណ្តុះបណ្តាល នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនផលិតភាពផង និងការកែលំអល័ក្ខខ័ណ្ឌការងារដោយមានការចូលរួមរបស់កម្មករនិយោជិតផង។ អង្គការពលកម្មអន្តរជាតិប្រើប្រាស់នូវជំនាញការអន្តរជាតិរបស់ខ្លួនរៀបចំ និងអនុវត្តនូវកម្មវិធីកែលំអទាំងនេះ។ ប្រធានបទនានានៃការបណ្តុះបណ្តាលរួមមានកិច្ចសហការនៅកន្លែងធ្វើការ និងការដោះស្រាយវិវាទ សុវត្ថិភាព និង សុខភាពការងារ ល័ក្ខខ័ណ្ឌការងារ សាកលភាវូបនីយកម្ម និងដំណើរការផ្លាស់ប្តូរ។ ការបណ្តុះបណ្តាលទាំងនេះធ្វើឡើងជាភាសា ខ្មែរ ចិន និងអង់គ្លេស ។

ការបណ្តុះបណ្តាលរបស់ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺរៀបចំឡើងដើម្បីតំរូវអោយអ្នកគ្រប់គ្នាអាចចែករំលែកនូវទស្សនៈ និងគំនិតរបស់ខ្លួន និងដើម្បីអោយគេអាចមានការវិវត្តន៏ផ្តើមចេញពីបទពិសោធន៏របស់គេផ្ទាល់។ កម្មវិធីនេះសង្កត់ធ្ងន់ទៅលើការកែលំអជាក់ស្តែង និងអាចវាស់វែងបាននៅថ្នាក់រោងចក្រសហគ្រាស ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក៏ធ្វើការផងដែរជាមួយមន្ត្រីរបស់រដ្ឋាភិបាលដើម្បីជួយកសាងសមត្ថភាពដល់ពួកគេ និងជាមួយអង្គការក្នុងស្រុកដើម្បីគេអាចផ្តល់ជូននូវការបណ្តុះបណ្តាលដល់ឧស្សាហកម្មនេះក្នុងរយៈពេលយូរអង្វែង ។

# លទ្ធភាពប្រើប្រាស់ពត៌មានកាន់តែប្រសើរ

បច្ចុប្បន្ននេះ លទ្ធផលនៃការឃ្លាំមើលល័ក្ខខ័ណ្ឌការងារត្រូវបានផ្សព្វផ្សាយក្នុងរបាយការណ៍ និងអាចស្រង់ចេញពីវែបសាយរបស់អង្គការពលកម្មអន្តរជាតិ។ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កំពុងធ្វើការដើម្បីលើកកំពស់ តម្លាភាព និងលទ្ធភាពចំពោះពតិមាន។ ប្រព័ន្ធគ្រប់គ្រងពតិមានជាលើកដំបូងក្នុងពិភពលោកកំពុងត្រូវបានអនុវត្តនៅឆ្នាំ ២០០៥ នេះ។ ប្រព័ន្ធថ្មីនេះគឺផ្អែកលើវែបសាយ ហើយនិងផ្តល់នូវរបាយការណ៍ទាន់ពេលវេលា ស្តីពីការឃ្លាំមើល ការបណ្តុះបណ្តាល និងការរីកចំរើន ហើយដែលមានជាភាសាខ្មែរ អង់គ្លេស និងភាសាចិន ។

ប្រព័ន្ធថ្មីនេះ នឹងបន្តទំលាប់នៃការលើកឡើងពីឈ្មោះរោងចក្រសហគ្រាស និងកំណត់ពីការរីកចំរើនរបស់គេទាក់ទិននឹងការកែលំអល័ក្ខខ័ណ្ឌការងារ។ ប៉ុន្តែវានឹងមានលក្ខណៈសាមញ្ញ និងអាចផលិតចេញនូវរបាយការណ៍បែបវិភាគអំពីនិន្នាការឧស្សាហកម្ម ការរីកចំរើន និងបញ្ហាផ្សេងៗទៀតក្នុងការអនុវត្តន៏តាម។ លទ្ធភាពទាំងនេះ គឺជាជំនួយដល់គោលនយោបាយ និងការធ្វើផែនការកម្មវិធីនៅក្នុងឧស្សាហកម្មនេះ។ ក្នុងករណីមានតំរូវការពតិមានលំអិតអំពីរោងចក្រជាក់លាក់ណាមួយ សិទ្ធិប្រើប្រាស់ពិសេសសំរាប់ចូលរកពតិមានទាំងនោះ នឹងផ្តល់ជូន ប៉ុន្តែលុះត្រាតែមានការព្រមព្រៀងពីម្ចាស់រោងចក្រ ។



# រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា



## ហេតុអ្វីគំរោងដំណើរការទៅកើត

គំរោងនេះដំណើរការទៅកើតដោយសារហេតុផលមួយចំនួន។ គំរោងនេះរួមបញ្ចូលនូវគ្រប់រោងចក្រទាំងអស់ ដែលនាំចេញនូវផលិតផលសំលៀកបំពាក់ និងតំណាងអោយផលប្រយោជន៏រួមរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងឧស្សាហកម្មនេះ។ គំរោងនេះមានតម្លាភាព អាចជឿទុកចិត្តបានពីអ្នកទិញអន្តរជាតិ ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងអាចឆ្លើយតបទៅនឹងតំរូវការ និងផលប្រយោជន៏របស់កម្មករនិយោជិត និងឧស្សាហកម្ម ។

គ្រប់រោងចក្រនាំចេញទាំងអស់នៅក្នុងប្រទេសត្រូវបានឃ្លាំមើលដោយគំរោងនេះ គឺដោយសារមានកិច្ចសហការពីក្រសួងពាណិជ្ជកម្មកម្ពុជា ។ ការចូលរួមក្នុងគំរោងនេះគឺជាល័ក្ខខ័ណ្ឌនៅកម្ពុជា ដើម្បីមានសិទ្ធិនាំចេញ។

កម្មវិធី *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ពុំមែនត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានការគោរពបទដ្ឋានការងារទាំងស្រុងនោះទេ ។ កម្មវិធីនេះផ្តោតលើការកែលំអជាបន្តបន្ទាប់ ។ ក្នុងខណៈពេលដែលបញ្ហានៅតែមាននៅឡើយ ភាពរីកចំរើនដ៏ជាក់លាក់នានាបានកើតឡើងដោយសារកម្មវិធីនេះអស់រយៈពេលជាង ៤ឆ្នាំ កន្លងមកហើយ ។ *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានអនុវត្តនូវអ្វីដូចដែលខ្លួនបានគ្រោងទុក ។ វានាំមកនូវការកែលំអ តាមដំណាក់កាលនិមួយៗ ។

*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* តំណាងអោយចំនុចប្រសព្វនៃផលប្រយោជន៏រួមរបស់ឧស្សាហកម្ម អ្នកទិញអន្តរជាតិ និងជាបំណងអ្នកប្រើប្រាស់នៅលោកខាងលិចដែលចង់ទិញផលិតផល ដែលពុំមានការកេងប្រវ័ញ្ចលើកម្មករ ព្រមទាំងបំណងដែលចង់អោយមានការងារកាន់តែច្រើន និងកាន់តែប្រសើរនៅតាមបណ្តាប្រទេសដែលក្រីក្របំផុត។ គ្រប់គំរោងកម្មវិធីទាំងអស់របស់អង្គការពលកម្មអន្តរជាតិ សហជីពកម្មករជាតិ អង្គការ និយោជក និងរដ្ឋាភិបាល គឺជាដៃគូនៅក្នុងការងារនេះ។